**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ៤១៧៣ ព.ណ.វ.ប.ព.ស

ថ្ងៃចន្ទ ៧កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ ២០២១

# សេចក្ដីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អ្នកសិក្សាស្រាវជ្រាវ សាស្ត្រាចារ្យ សិស្ស និស្សិត និងសាធារណជនឱ្យបានជ្រាបថា៖ វិទ្យាស្ថានបណ្ដុះបណ្ដាលពាណិជ្ជកម្ម និងស្រាវជ្រាវ នៃក្រសួងពាណិជ្ជកម្ម កំពុងរៀបចំនូវគម្រោងព្រឹត្តិប័ត្រស្រាវជ្រាវអេឡិចត្រូនិកប្រចាំខែ (E-Bulletin Project) ក្នុងគោលបំណងដើម្បីធ្វើការចងក្រងប្រមូលផ្ដុំ និងបោះពុម្ពផ្សាយជាប្រចាំរៀងរាល់ខែ នូវរាល់ស្នាដៃស្រាវជ្រាវសំខាន់ៗនានាពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម ព្រមទាំងប្រធានបទសំខាន់ៗផ្សេងទៀត ដែលមានអត្ថន័យខ្លឹមសារសំដៅចូលរួមលើកស្ទួយអភិវឌ្ឍន៍សេដ្ឋកិច្ច ពាណិជ្ជកម្ម និងជាស្នាដៃដើមប្រកបដោយក្រមសីលធម៌ ពុំមានការញោះញុង វាយប្រហា និងមិនបម្រើឱ្យក្រុម ឬគណបក្សណាមួយឡើយ។

ក្នុងអត្ថន័យនេះ វិទ្យាស្ថានបណ្ដុះបណ្ដាលពាណិជ្ជកម្ម និងស្រាវជ្រាវ នៃក្រសួងពាណិជ្ជកម្ម សូមស្វាគមន៍អ្នកសិក្សាស្រាវជ្រាវ សាស្ត្រាចារ្យ សិស្ស និស្សិត និងសាធារណជនទូទៅដែលមានចំណាប់អារម្មណ៍សូមផ្ញើខ្លឹមសារអត្ថបទស្រាវជ្រាវរបស់ខ្លួន ដើម្បីចូលរួមប្រកួតប្រជែងក្នុងការជ្រើសរើសចុះផ្សាយនៅលើគម្រោងព្រឹត្តិប័ត្រស្រាវជ្រាវអេឡិចត្រូនិកប្រចាំខែ (E-Bulletin Project) ច្បាប់ទី១ លេខទី១ ចាប់ផ្ដើមពីខែតុលា ឆ្នាំ២០២១នេះតទៅ។

## I. ប្រធានបទសម្រាប់ការស្រាវជ្រាវ

- ពាណិជ្ជកម្មក្នុងស្រុក និងអន្តរជាតិ
- ស្ថានភាពសេដ្ឋកិច្ចក្នុងស្រុក និងអន្តរជាតិ
- កសិ-ឧស្សាហកម្ម និងកសិ-ពាណិជ្ជកម្ម
- បដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ និងនវានុវត្តន៍
- បញ្ហាសង្គម
- សមភាពយេនឌ័រ
- ប្រធានបទដទៃទៀតដែលពាក់ព័ន្ធនឹងវិទ្យាស្ថាន

## II. ប្រភេទ និងមាតិកាអត្ថបទដែលត្រូវចុះផ្សាយ

- អត្ថបទស្រាវជ្រាវ
- ករណីសិក្សា



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

- ការវិភាគគោលនយោបាយ
- បទអត្ថាធិប្បាយ ឬបទវិចារណាកថា
- ទស្សនាវដ្តី ( Journal )

## III. អត្ថប្រយោជន៍សម្រាប់អ្នកស្រាវជ្រាវ

- ឱកាសទទួលបានការផ្សព្វផ្សាយស្នាដៃរបស់ខ្លួន បានទូលំទូលាយទៅកាន់សាធារណជន
- ឱកាសទទួលបានមតិយោបល់កែសម្រួលពីអ្នកជំនាញ ដើម្បីបង្កើនគុណភាពនៃអត្ថបទស្រាវជ្រាវ
- ឱកាសទទួលបានការទទួលស្គាល់ជាអ្នកស្រាវជ្រាវឆ្នើមរបស់វិទ្យាស្ថាន ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ឱកាសទទួលបានការផ្សព្វផ្សាយស្នាដៃរបស់ខ្លួន សម្រាប់វេទិកា និងព្រឹត្តិការណ៍នានាកម្រិតថ្នាក់ជាតិ និងអន្តរជាតិ
- ឱកាសបង្កើនកេរ្តិ៍ឈ្មោះ និងស្នាដៃក្នុងអាជីពជាអ្នកស្រាវជ្រាវ
- ទទួលបានការរក្សាសិទ្ធអ្នកនិពន្ធ។

## IV. លក្ខខណ្ឌនៃការទទួលកិច្ចការស្រាវជ្រាវ

- កាលបរិច្ឆេទនៃការទទួល៖ ត្រឹមថ្ងៃទី២៥ រៀងរាល់ចុងខែនីមួយៗ
- កាលបរិច្ឆេទនៃការបោះពុម្ពផ្សាយ៖ ខែតុលា ឆ្នាំ២០២១ (ច្បាប់ទី១ លេខទី១) និងរៀងរាល់ខែបន្តបន្ទាប់
- ភាសា៖ ខ្មែរ ឬអង់គ្លេស
- អាសយដ្ឋានសម្រាប់ទទួល៖ ttri.cambodia@gmail.com
- សេចក្តីព្រាង នៃអត្ថបទស្រាវជ្រាវដែលបានបញ្ជូនមក ត្រូវជាទម្រង់ Microsoft Word ចាប់ពី៦ទៅ ១០ទំព័រ ដែលមានខ្លឹមសារគ្រប់គ្រាន់ក្នុងការចូលរួមកែលម្អអភិវឌ្ឍន៍សេដ្ឋកិច្ច ពាណិជ្ជកម្ម សង្គម
- អត្ថបទស្រាវជ្រាវ ដែលមិនទាន់បានចុះផ្សាយពីមុនមក
- រាល់ខ្លឹមសារ និងគំនិតនៃការស្រាវជ្រាវ ដែលបានចម្លងទាំងស្រុងពីប្រភពណាមួយ នឹងត្រូវបដិសេធ មិនទទួលយក
- រាល់ទិន្នន័យ ស្ថិតិ ព័ត៌មាន ត្រូវបញ្ជាក់-ប្រភព ឯកសារយោងច្បាស់លាស់។
- អត្ថបទស្រាវជ្រាវ ដែលបានបញ្ជូនមកមិនអាចត្រូវបានប្រើសម្រាប់ចុះផ្សាយនៅក្នុងវេទិកាដទៃទៀត នោះទេ លុះត្រាតែកិច្ចការនោះត្រូវបានបដិសេធជាមុនសិន។

សូមទំនាក់ទំនងដើម្បីទទួលបានព័ត៌មានបន្ថែម៖

១. លោក ប៉ាវ ភិរក្ស តួនាទីប្រធានការិយាល័យស្រាវជ្រាវ នៃវិទ្យាស្ថាន

ទូរស័ព្ទលេខ៖ 011 200 255 សារអេឡិកត្រូនិក៖ phireakpao@yahoo.com

២. លោកស្រី យ៉ាងនី ចរិយា តួនាទីមន្ត្រីនៃការិយាល័យស្រាវជ្រាវនៃវិទ្យាស្ថាន

ទូរស័ព្ទលេខ៖ 012 976 767 សារអេឡិកត្រូនិក៖ y.chakriya@gmanil.com

អាស្រ័យហេតុនេះ សូមអ្នកសិក្សាស្រាវជ្រាវ សាស្ត្រាចារ្យ សិស្ស និស្សិត និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមឱ្យបានផុសផុលចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងពាណិជ្ជកម្ម *